ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៤/២១-ខេន ស្ព័ត ស៊ូ

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ**

អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទ ៖ ០៧៨ ៧៧៧ ៦១៩ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ ៖

| | | |
|---|---|---|
| ១- | លោក Brian Lee | នាយកផ្នែករដ្ឋបាល |
| ២- | លោក គិម ពេជ្រដា | ប្រធានផ្នែកច្បាប់សមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC) |
| ៣- | លោក សយ ធារិទ្ធិ | មន្រ្តីជាន់ខ្ពស់ផ្នែកច្បាប់សមាគមរោងចក្រកាត់ដេរកម្ពុជា(GMAC) |
| ៤- | លោក សុះ មើ | ប្រធានផ្នែកអនុលោមច្បាប់ |
| ៥- | លោក អ៊ុក អ៊ុន | បុគ្គលិកផ្នែករដ្ឋបាល |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ**

អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទ ៖ ០៨១ ៨៨៧ ៧០១/០៨១ ៤៧៨ ០១៥ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

| | | |
|---|---|---|
| ១- | លោក ម៉ៃ វឌ្ឍនា | អនុប្រធានសហព័ន្ធសហជីពយុវជនខ្មែរ |
| ២- | លោកស្រី ប៉ែន សុភ័ន | ប្រធានសហជីពយុវជនខ្មែរ(មូលដ្ឋាន) |
| ៣- | លោកស្រី កេត ស្រីភ័ក្ត្រ | អនុប្រធានសហជីពយុវជនខ្មែរ(មូលដ្ឋាន) |

៤- លោក ស៊ុក វី លេខាសហជីព(មូលដ្ឋាន)

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីក្រុមហ៊ុនឯកភាពផ្តល់សិទ្ធិជូនកម្មករនិយោជិតជាអ្នកស្នើសុំឈប់សម្រាកបំណាច់ឆ្នាំ ហើយឱ្យស្របតាមនីតិវិធីនៅក្នុងបទបញ្ជាផ្ទៃក្នុង ដោយឡែកភាគីកម្មករនិយោជិតនៅតែទាមទារទូទាត់ការឈប់សម្រាកបំណាច់ឆ្នាំដែលនៅសល់ជាលុយវិញ។

២- ភាគីក្រុមហ៊ុនមិនបានរើសអើងសហជីពនោះទេ ដោយឡែកភាគីកម្មករនិយោជិតនៅតែបញ្ជាក់ថាក្រុមហ៊ុនមានការរើសអើងសហជីព។

៣- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្លាស់ប្តូរប្រធានផ្នែករដ្ឋបាលឈ្មោះ សុះ មើ ចេញពីតួនាទី។

៤- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្លាស់ប្តូររដ្ឋបាលឈ្មោះ អ៊ុក អ៊ុន ចេញពីតួនាទីកាន់កាប់ផ្នែកសហជីព។

៥- ក្រុមហ៊ុនមិនឯកភាពផ្តល់ឈ្មោះ អត្តលេខ កម្មករ កម្មការិនី ដែលបានលាឈប់ធ្វើការក្នុងខែនីមួយៗជូនសហជីពយុវជនខ្មែរបានទេ និងក្រុមហ៊ុនដាក់បញ្ចូលលុយភាគទានសហជីពចូលគណនីសហជីពនៅថ្ងៃទី១២ ជារៀងរាល់ខែ ដោយឡែកភាគីកម្មករនិយោជិតស្នើសុំបញ្ចូលលុយភាគទានសហជីពនៅថ្ងៃទី១០។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ០៧៤ កប/កធ ចុះថ្ងៃព្រហស្បតិ៍ ៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃពុធ ៦កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានទទួលលិខិតស្នើសុំឱ្យជួយដោះស្រាយវិវាទការងាររបស់កម្មករនិយោជិត នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលម្អលក្ខខណ្ឌការងារចំនួន ១២ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងបានផ្សះផ្សាជាលើកចុងក្រោយទៅតាមនីតិវិធីច្បាប់ នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ ដោយទទួលបានលទ្ធផលសះជាចំនួន ៧ចំណុច និងមិនសះជាចំនួន ៥ចំណុច។ ចំណុចមិនសះជាចំនួន ៥ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ០៧៤ កប/កធ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជា នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ២ និង ០០ នាទីរសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វែករកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៥ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ដោយភាគីបានព្រមព្រៀងគ្នាចំនួន ៣ចំណុច គឺចំណុចវិវាទទី៣, ទី៤ និងទី៥ ក្នុងនោះភាគីកម្មករនិយោជិតយល់ព្រមបញ្ចូលចំណុចវិវាទទី៤ និងទី៥ជាចំណុចវិវាទតែមួយ និងស្នើសុំឱ្យក្រុមអាជ្ញាកណ្តាលសរសេរកិច្ចព្រមព្រៀងនៃចំណុចដែលបានព្រមព្រៀងនេះនៅក្នុងសេចក្តីបង្គាប់។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចដែលនៅសល់ចំនួន ២ចំណុច គឺចំណុចវិវាទទី១ និងចំណុចវិវាទទី២។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

**សាក្សី និងអ្នកជំនាញក្រៅពីភាគី ៖**

- **សាក្សី ៖**

១-លោកស្រី ស្រ៊ុន សុម៉ាលី ជាកម្មករនិយោជិត (ផ្នែកខ្សែទឹកហូរ)

- **អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ-សិប្បកម្ម ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ៦៨២៣ ឧសក ឧវប១២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

២- បណ្ណប៉ាតង់ឆ្នាំ២០២១ ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ PTL 2021011106 អពដ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២១។

៣- ការកិច្ចរបស់អាជីវកម្មដ្ឋាន(ដកស្រង់ពីក្រឹត្យច្បាប់លេខ២២ ក្រ.ច ចុះថ្ងៃទី១៤-០៦-១៩៨៥)។

៤- ប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម លេខ ៦២៥ឧសក១ប្រក១២ ស្ដីពីប្រកាសបង្កើតរោងចក្រ ខេន ស្ព័ត ស៊ូ ចុះថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

៥- លិខិតលេខ ០៤/០២១ ខសស ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ របស់ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីការជ្រើសរើសអាជ្ញាកណ្ដាល។

៦- លិខិតផ្ទេរសិទ្ធិរបស់លោក នីក លីន (Nick Lin) ជានាយកប្រតិបត្តិក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ខូអិលធីឌី ផ្ទេរសិទ្ធិជូនលោក ប្រាយអ៊ិន លី (Brian Lee) លោក គិម ពេជ្រដា លោក សយ ជារិទ្ធ លោក សុះ មើ និងលោក អ៊ុក អ៊ុន ជាតំណាងដោះស្រាយ វិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ មានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយវិវាទការរួម ចុះថ្ងៃចន្ទ ៤កើត ខែផល្គុន ឆ្នាំជូត ទោស័ក ពស២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១។

៧- សារណាសង្ខេបវិវាទការងារ។

៨- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះទិដ្ឋាការលេខ ១១/២០ ចុះថ្ងៃព្រហស្បតិ៍ ៩រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ដោយអភិបាលរងខេត្តកំពង់ឆ្នាំង។

៩- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១។

១០- លិខិតលេខ ០២១/១០ ខសល ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ របស់ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ គោរពជូន ប្រធានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីសារណាការពារ របស់ក្រុមហ៊ុន ខេន ស្ព័តស៊ូ ខូអិលធីឌី។

១១- លិខិតបញ្ចេញមតិយោបល់/អនុម័តការពិន័យ របស់ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះថ្ងៃ១៣ ខែមករា ឆ្នាំ២០២១។

១២- លិខិតលេខ ០២១/១១ ខសល ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ គោរពជូន ប្រធានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីប្ដឹងជំទាស់ឯកសារ និងវីដេអូឃ្លីប របស់សហជីពយុវជនខ្មែរប្រចាំនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតលេខ ០៦/២១ ស.ស.យ.ខ របស់សហព័ន្ធសហជីពយុវជនខ្មែរ(ស.ស.យ.ខ) ចុះថ្ងៃអង្គារ៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ស្ដីពីការបញ្ជូនលោក ម៉ៃ ខ្លៃនា អនុប្រធានសហព័ន្ធយុវជនខ្មែរ ជាមន្ត្រីកិច្ចការច្បាប់ និងចរចាដោះស្រាយរបស់សហព័ន្ធសហជីពយុវជនខ្មែរ ចូលរួមសវនាការសម្របសម្រួលនូវវិវាទការងាររបស់កម្មករនិយោជិតជាមួយក្រុមហ៊ុន ខេន ស្ព័តស៊ូ នៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល។

THE ARBITRATION COUNCIL

២- ពាក្យសុំបញ្ចូលកស្តុតាង ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់ឈ្មោះ ឡាយ ស្រីម៉ា, សៀន សុខលៀប និង ប៉ែន សុភ័ន គោរពជូន ឯកឧត្តមព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ស្តីពី សំណើសុំបញ្ចូលកស្តុតាង។

៣- ដីកាកោះ ចុះថ្ងៃព្រហស្បតិ៍ ៣រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

៤- សារអេឡិចត្រូនិក។

៥- ស្នាមមេដៃកម្មករ-កម្មការិនីក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ស្នើសុំពឹងពាក់-ជួយអម និងសម្របសម្រួលដោះស្រាយនូវលក្ខខណ្ឌការងារ។

៦- ឯកសារវីដេអូ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ០៧៤ កប/កធ ចុះថ្ងៃព្រហស្បតិ៍ ៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ ២០២១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ០០១/២១ ក.ប/ក.ធ.ល.ប.រ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០២០ កប/អក/វក/លកអ. ថ្ងៃអង្គារ ១២រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០២១ កប/អក/វក/លកអ. ថ្ងៃអង្គារ ១២រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ គឺមានសកម្មភាពចម្បងផលិតស្បែកជើង និងមានដូលកម្មករនិយោជិតសរុបចំនួន ៨៩០៥នាក់ *(យោងតាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ០៧៤ កប/កធ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១)*។
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០១/២១ ក.ប/ក.ធ ល.ប.រ ចុះថ្ងៃទី២៩ ខែមករា

THE ARBITRATION COUNCIL

ឆ្នាំ២០២១ ដែលមានកម្មករនិយោជិត ចំនួន ៣នាក់ ៖ ១. ប៉ែន សុភ័ន, ២. កេត ស្រីវត្ថ និង ៣. ស្តុក វី ដែលជាអ្នកតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ក្នុងការដោះស្រាយវិវាទការងាររួម។

**ចំណុចវិវាទទី១ ៖ ភាគីក្រុមហ៊ុនឯកភាពផ្តល់សិទ្ធិជូនកម្មករនិយោជិតជាអ្នកស្នើសុំឈប់សម្រាកបំណាច់ឆ្នាំ ហើយឱ្យស្របតាមនីតិវិធីនៅក្នុងបទបញ្ជាផ្ទៃក្នុង ដោយឡែកភាគីកម្មករនិយោជិតនៅតែទាមទារទូទាត់ការឈប់សម្រាកបំណាច់ឆ្នាំដែលនៅសល់ជាលុយវិញ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ដែលនិយោជកបានកាត់ខុស ជូនកម្មករនិយោជិតវិញ។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - និយោជកតែងតែប្រកាស និងណែនាំឱ្យកម្មករនិយោជិតប្រើប្រាស់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល និងប្រាប់ពីចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលដែលកម្មករនិយោជិតអាចសន្សំទុកទៅប្រើនៅឆ្នាំបន្ទាប់ គឺមានចំនួនតែ ៦ថ្ងៃ ឬលើសពីនេះតាមអតីតភាពរបស់កម្មករនិយោជិតនីមួយៗ។
  - ចំពោះការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលដែលកម្មករនិយោជិតមិនបានប្រើអស់ គឺគាត់អាចរក្សាការឈប់សម្រាកប្រចាំឆ្នាំចំនួន ៦ថ្ងៃ ដើម្បីយកទៅប្រើនៅឆ្នាំបន្ទាប់ទៀតបាន ហើយការយកទៅប្រើទៅឆ្នាំបន្ទាប់នេះ គឺមិនអាចលើសពី ៣ឆ្នាំបន្តបន្ទាប់ទេ។ និយោជកមិនមានការទូទាត់ជាប្រាក់ជំនួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ ជូនកម្មករនិយោជិតនោះទេ ករណីដែលកម្មករនិយោជិតនៅតែបន្តការងារ។
  - ករណីមានកម្មករនិយោជិតណាមួយ ត្រូវបាននិយោជកកាត់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួលខុស និយោជកនឹងសងថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលដែលកាត់ខុសនោះ ឱ្យទៅកម្មករនិយោជិតបានឈប់សម្រាកវិញ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ជាការអនុវត្តរបស់និយោជក គឺកម្មករនិយោជិតមានសិទ្ធិសន្សំថ្ងៃឈប់សម្រាកដោយមានប្រាក់ឈ្នួលបាន ទៅឆ្នាំបន្ទាប់បានតែចំនួន ៦ថ្ងៃ ក្នុងមួយឆ្នាំ និងអាចទុកបានតែរយៈពេលបីឆ្នាំទេ សម្រាប់ឆ្នាំនីមួយៗ។ ដូចនេះ និយោជកត្រូវសងថ្ងៃឈប់សម្រាកដោយមានប្រាក់ឈ្នួលមកវិញ ព្រោះកម្មករនិយោជិតនៅសល់ថ្ងៃឈប់សម្រាកនេះច្រើន ដោយសារនិយោជកមិនបានរៀបចំឱ្យកម្មករនិយោជិតប្រើប្រាស់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលនេះអស់នោះទេ។
  - ពេលកម្មករនិយោជិតដាក់ច្បាប់ឈប់សម្រាកដោយប្រើថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ប្រធានក្រុម និងប្រធានផ្នែកមិនបានអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកនោះទេ។
  - កម្មករនិយោជិតនៅតែចង់ឱ្យអាជ្ញាកណ្តាលកាត់សេចក្តីនៅក្នុងចំណុចវិវាទនេះ បើទោះបីជានិយោជកអះអាងថា នឹងសងថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ដែលបានកាត់ខុសនោះឱ្យទៅកម្មករនិយោជិតបានឈប់សម្រាកវិញក៏ដោយ។
- សាក្សីភាគីកម្មករនិយោជិតបញ្ជាក់ថា ៖
  - គាត់តែងតែសុំការអនុញ្ញាតច្បាប់ឈប់សម្រាកមុន ១សប្តាហ៍ តែនិយោជកមិនបានអនុញ្ញាតឱ្យឈប់នោះទេ។

THE ARBITRATION COUNCIL

- នៅខែវិច្ឆិកា ឆ្នាំ២០២០ ខ្លួនមានធុរៈព្រោះកូនឈឺ ហើយបានសុំការអនុញ្ញាតច្បាប់ឈប់សម្រាកពីប្រធានក្រុម និងប្រធានផ្នែក តែមិនបានការអនុញ្ញាតច្បាប់ឈប់សម្រាកនោះទេ ហើយគាត់ក៏ឈប់ ករណីនេះប្រធានរបស់គាត់ដាក់គាត់អវត្តមានពីការងារ។
- នៅខែធ្នូ ឆ្នាំ២០២០ គាត់បានសុំអនុញ្ញាតច្បាប់ឈប់សម្រាកចំនួន ២ថ្ងៃ ដើម្បីទៅច្រូតស្រូវ តែប្រធានក្រុមមិនបានអនុញ្ញាតច្បាប់ឱ្យឈប់នោះទេ ដោយឱ្យគាត់ទៅសុំការអនុញ្ញាតច្បាប់ពីប្រធានផ្នែក ហើយប្រធានផ្នែកឱ្យទៅជួបប្រធានផ្នែកចិនទៀត ក៏គាត់មិនបានការអនុញ្ញាតច្បាប់ឈប់សម្រាកនោះដែរ ជាចុងក្រោយ គាត់ក៏បានឈប់ ហើយប្រធានរបស់គាត់បានដាក់គាត់អវត្តមានពីការងារនៅថ្ងៃនោះ។

- ភាគីនិយោជកបញ្ជាក់មូលហេតុ និងឆ្លើយតបទៅនឹងការទាមទាររបស់ភាគីកម្មករនិយោជិតថា ៖
  - និយោជកបានអនុវត្តការប្រើប្រាស់ និងកាត់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលរបស់កម្មករនិយោជិតតាមច្បាប់ស្តីពីការងារ។
  - និយោជកបានធ្វើកិច្ចព្រមព្រៀងជាមួយសហជីពទាំងអស់ ដើម្បីកំណត់អំពីការប្រើប្រាស់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ហើយចំពោះថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលនៅសល់ពីការកំណត់នេះ កម្មករនិយោជិតអាចប្រើបានដោយដាក់ច្បាប់ឈប់សម្រាកទៅតាមនីតិវិធីរបស់ក្រុមហ៊ុន។
  - ករណីប្រធានក្រុម ឬប្រធានផ្នែកមិនអនុញ្ញាតច្បាប់ឱ្យកម្មករនិយោជិតឈប់សម្រាក ពួកគាត់មិនបានទាក់ទងមកផ្នែករដ្ឋបាល ដើម្បីឱ្យផ្នែករដ្ឋបាលជួយសម្រួលទៅប្រធានក្រុម ឬប្រធានផ្នែករបស់ពួកគាត់នោះទេ តែកម្មករនិយោជិតឈប់តែម្តងដោយគ្មានការអនុញ្ញាតច្បាប់។
  - និយោជកតែងតែជួយសម្រួលឱ្យកម្មករនិយោជិតបានឈប់សម្រាក នៅពេលវេលាសមស្របណាមួយ។
  - និយោជក លើកទឹកចិត្តឱ្យកម្មករនិយោជិតឈប់សម្រាកដោយប្រើថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលឱ្យអស់ តែបើមិនអស់ទេ គឺអាចយកទៅប្រើបន្តនៅឆ្នាំបន្ទាប់បានចំនួន ៦ថ្ងៃ និងទុកបានរយៈពេល ៣ឆ្នាំ។
  - និយោជកនឹងធ្វើការពិនិត្យឡើងវិញពីការអនុវត្តការកាត់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលរបស់កម្មករនិយោជិត ហើយករណីរកឃើញថាបានកាត់ខុស និយោជកនឹងសងជាថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលជូនកម្មករនិយោជិតវិញ។
  - អាជ្ញាកណ្តាលមិនគួរពិចារណាចំណុចវិវាទនេះម្តងទៀតទេ ដោយហេតុថាក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្លាប់បានកាត់ចំណុចនេះរួចម្តងហើយ នៅក្នុងសំណុំរឿងលេខ ០៦៣/២០ ត្រង់ចំណុចវិវាទទី៧។

**ចំណុចវិវាទទី២ ៖ ភាគីក្រុមហ៊ុនមិនបានរើសអើងសហជីពនោះទេ ដោយឡែកភាគីកម្មករនិយោជិតនៅតែបញ្ជាក់ថា ក្រុមហ៊ុនមានការរើសអើងសហជីព**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារកុំឱ្យនិយោជករើសអើងសហជីពយុវជនខ្មែរ។
- ភាគីទាំងពីរទទួលស្គាល់ថា ៖

THE ARBITRATION COUNCIL

- ០ និយោជកមានបម្រាមមិនឱ្យមានការដើរថតសកម្មភាពកម្មករនិយោជិតនៅកន្លែងការងារក្នុងម៉ោងធ្វើការ។
- ០ ករណីមានអ្នកដើរថតសកម្មភាពកម្មករនិយោជិតនៅកន្លែងធ្វើការក្នុងម៉ោងការងារ កម្មករនិយោជិតអាចប្ដឹងមករដ្ឋបាលដោយមានភស្តុតាងបញ្ជាក់ ដើម្បីរដ្ឋបាលចាត់វិធានការ។
- ០ នៅក្នុងរោងចក្រមានសហជីពចំនួន ៨ ហើយផ្នែករដ្ឋបាលធ្លាប់បានជួបប្រជុំជាមួយសហជីពទាំងនេះ រួមទាំងសហព័ន្ធសហជីពដែលពាក់ព័ន្ធ ដើម្បីចាត់វិធានការ លែងឱ្យមានការដើរថតសកម្មភាពរបស់កម្មករនិយោជិតនៅកន្លែងធ្វើការក្នុងម៉ោងការងារតទៅទៀត ហើយឱ្យសហជីពទាំងអស់គោរពតួនាទីរបស់ខ្លួន។

- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ០ និយោជកមានការរើសអើងសហជីពយុវជនខ្មែរ ព្រោះកម្មករនិយោជិតឈ្មោះ ខណៈ វិច្ឆ័យ ដែលមកពីសហជីពកម្មករកម្ពុជា បានដើរថតសកម្មភាពកម្មករនិយោជិតដែលជាសមាជិកសហជីពយុវជនខ្មែរក្នុងម៉ោងការងារតាមចិត្ត ដោយគ្មានការហាមឃាត់អ្វីទាំងអស់ពីនិយោជក។
  - ០ មានតែសហជីពចំនួន ៤ ទៅ៥ តែប៉ុណ្ណោះ ដែលគោរពតាមវិធានការរបស់និយោជក និងតាមការប្រជុំសហជីព។ ដោយឡែក សហជីព ២ ទៅ៣ ផ្សេងទៀត នៅតែដើរថតសកម្មភាពកម្មករនិយោជិតក្នុងរោងចក្រនៅក្នុងម៉ោងការងារ ហើយនិយោជកមិនបានចាត់វិធានការទៅលើសហជីពទាំងនោះទេ។
  - ០ នៅពេលរាយការណ៍ទៅផ្នែករដ្ឋបាល ផ្នែករដ្ឋបាលមិនបានចាត់វិធានការអ្វីនោះទេ ដោយសំអាងថាគ្មានភស្តុតាងជាក់លាក់។ សហជីពយុវជនខ្មែរធ្លាប់ដាក់ភស្តុតាងទៅរដ្ឋបាល តែរដ្ឋបាលក៏មិនបានចាត់វិធានការអ្វីនោះដែរ។
  - ០ និយោជកធ្លាប់ប្រជុំជាមួយសហជីពដោយបានប្រាប់ថា មិនមានការធ្វើការងារបន្ថែមម៉ោងនោះទេគ្រប់សមាជិកសហជីពទាំងអស់ តែនិយោជកឱ្យកម្មករនិយោជិតដែលជាសមាជិកសហជីពផ្សេងទៀតធ្វើកាបន្ថែមម៉ោងរហូត ដោយមិនឱ្យកម្មករនិយោជិតដែលជាសហជីពយុវជនខ្មែរធ្វើការងារបន្ថែមម៉ោងនោះទេ។
  - ០ និយោជកត្រូវតែបញ្ឈប់សកម្មភាពសហជីពរបស់លោក ខណៈ វិច្ឆ័យ ដែលបានដើរថតសកម្មភាពកម្មករនិយោជិត ដោយអះអាងថាខ្លួនមានសិទ្ធិ។

- ភាគីនិយោជកបញ្ជាក់ថា និយោជកមិនមានការរើសអើងសហជីពណាមួយនោះទេ ដោយមូលហេតុថា ៖
  - ០ ជាគោលការណ៍ កម្មករនិយោជិតទាំងអស់ត្រូវគោរពតាមកិច្ចសន្យាការងារ ដែលត្រូវបំពេញតួនាទីរបស់ខ្លួនក្នុងម៉ោងការងារ។
  - ០ និយោជកមិនបានប្រាប់ឱ្យសហជីពណាមួយដើរថតសកម្មភាពកម្មករនិយោជិតក្នុងម៉ោងការងារនោះទេ។
  - ០ ករណីឃើញមានសកម្មភាពដើរថតកម្មករនិយោជិតក្នុងម៉ោងការងារ កម្មករនិយោជិតត្រូវប្ដឹងមកផ្នែករដ្ឋបាលដោយមានភស្តុតាងបញ្ជាក់អំពីសកម្មភាព ឬមានសាក្សីដែលអាចឱ្យរដ្ឋបាលសួរនាំបញ្ជាក់ព័ត៌មាន ហើយនិយោជកនឹងចាត់វិធានការយ៉ាងយូររយៈពេល ៧ថ្ងៃ។
  - ០ កន្លងមកនិយោជកបានចាត់វិធានការចំពោះអ្នកដែលប្រព្រឹត្តខុស ដោយបានធ្វើការព្រមានដោយផ្ទាល់មាត់ និងជាលាយលក្ខអក្សរជាលើកទី១ និងលើកទី២ រួចហើយ។

THE ARBITRATION COUNCIL

- ការដាក់ទោសពិន័យ គឺផ្អែកទៅលើនីតិវិធីរបស់ក្រុមហ៊ុន ហើយក្រុមហ៊ុនលើកទឹកចិត្តដល់កម្មករនិយោជិតចូលរួមរាយការណ៍ដោយត្រូវមានភស្តុតាងគ្រប់គ្រាន់ នោះក្រុមហ៊ុននឹងចាត់វិធានការតាមបទបញ្ជាផ្ទៃក្នុង និងច្បាប់។

**ចំណុចវិវាទទី៣ ៖ ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្លាស់ប្តូរប្រធានផ្នែករដ្ឋបាលឈ្មោះ សុះ មើ ចេញពីតួនាទី**

- ចំពោះចំណុចវិវាទនេះ នៅថ្ងៃសវនាការ ភាគីនិយោជក និងភាគីកម្មករនិយោជិត បានព្រមព្រៀងគ្នាថា៖ ក្រុមហ៊ុននឹងអនុវត្តការដាក់ទោសវិន័យតាមច្បាប់ទៅលើឈ្មោះ សុះ មើ ក្នុងករណីដែលរកឃើញថាគាត់បានប្រព្រឹត្តកំហុស។
- ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនពិចារណាលើចំណុចវិវាទនេះទេ។

**ចំណុចវិវាទទី៤ និងទី៥ ៖ ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្លាស់ប្តូររដ្ឋបាលឈ្មោះ អ៊ុក អ៊ុន ចេញពីតួនាទីកាន់កាប់ផ្នែកសហជីព និងទាមទារឱ្យនិយោជកផ្តល់ឈ្មោះ អត្តលេខ កម្មករកម្មការិនី ដែលបានលាឈប់ធ្វើការក្នុងខែនីមួយៗ ជូនសហជីពយុវជនខ្មែរ**

- ចំពោះចំណុចវិវាទនេះ នៅថ្ងៃសវនាការ ភាគីនិយោជក និងភាគីកម្មករនិយោជិត បានព្រមព្រៀងគ្នាដូចខាងក្រោម ៖
    - ភាគីសហជីពនឹងផ្តល់ចំនួនកម្មករនិយោជិតដែលចូលជាសមាជិកសហជីព និងលិខិតយល់ព្រមកាត់ប្រាក់ភាគទានសហជីព ដោយមានព័ត៌មានត្រឹមត្រូវអំពីកម្មករនិយោជិត ឱ្យទៅនិយោជកឱ្យបានមុនតាមចំនួនថ្ងៃដែលបានកំណត់នៅក្នុងប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យនិយោជកមានពេលរៀបចំកាត់ភាគទានសហជីព។
    - ករណីមានបាត់ ឬមានការកាត់បន្ថយចំនួនកម្មករនិយោជិតដែលជាសមាជិកសហជីព ក្នុងការកាត់ប្រាក់ភាគទានសហជីព និយោជកនឹងផ្តល់មូលហេតុទៅសហជីព។
- ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនពិចារណាលើចំណុចវិវាទនេះទេ។

## ហេតុផលនៃសេចក្តីសម្រេច ៖

**ចំណុចវិវាទទី១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលដែលនិយោជកបានកាត់ខុស ជូនកម្មករនិយោជិតវិញ**

នៅក្នុងសវនាការភាគីនិយោជកបានឆ្លើយតបទៅនឹងការទាមទាររបស់ភាគីកម្មករនិយោជិតថា បើមានកម្មករនិយោជិតណាមួយ ត្រូវបាននិយោជកកាត់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលខុស និយោជកនឹងសងថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលដែលនិយោជកបានកាត់ខុសនោះឱ្យទៅកម្មករនិយោជិតបានឈប់សម្រាកវិញ។ ហេតុដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាំងពីរមិនមានវិវាទពាក់ព័ន្ធទៅនឹងការសងការឈប់សម្រាកប្រចាំឆ្នាំដែលនិយោជកកាត់ខុស នៅក្នុងចំណុចដែលទាមទារនេះទៀតទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលនៅសល់ ដែលនិយោជកបានកាត់ខុស ជូនកម្មករនិយោជិតវិញ។

THE ARBITRATION COUNCIL

**ចំណុចវិវាទទី២ ៖ ភាគីកម្មករនិយោជិតទាមទារកុំឱ្យនិយោជករើសអើងសហជីពយុវជនខ្មែរ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកមានការរើសអើងសហជីពយុវជនខ្មែរដែរឬទេ?

មាត្រា ១២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ បានចែងថា ៖ *"...គ្មាននិយោជកណាម្នាក់អាចយកបញ្ហាការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព ដើម្បីជាលេសធ្វើសេចក្តីសម្រេចអំពី ៖ ការជួល ......វិន័យ ឬការផ្តាច់កិច្ចសន្យាការងារ ..."*។

មាត្រា ៦២ នៃច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ ចែងថា ៖ *"និយោជកមិនត្រូវរើសអើង ដោយយកលេសអំពីការជាប់ទាក់ទងនឹងការកាន់តំណែងជាថ្នាក់ដឹកនាំរបស់សហជីព ឬការចូលរួមរបស់កម្មករនិយោជិត ក្នុងសកម្មភាពសហជីព ដើម្បីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសឱ្យចូលធ្វើការដឹកនាំ ការបែងចែកការងារ ការដំឡើងតួនាទីមុខតំណែង ការផ្តល់ប្រាក់ឈ្នួល ការផ្តល់អត្ថប្រយោជន៍ វិធានការដាក់វិន័យ និងការបញ្ចប់កិច្ចសន្យាការងារដែលរួមបញ្ចូលទាំងការបញ្ឈប់ ឬការមិនបន្តកិច្ចសន្យាការងារដែលមានជាបន្តគ្នាដោយខុសនីតិវិធី"*។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការបកស្រាយយ៉ាងស៊ីសង្វាក់គ្នាថា ភាគីកម្មករនិយោជិតមានបន្ទុកផ្តល់ភស្តុតាងក្នុងការចោទប្រកាន់ថា និយោជករើសអើងសហជីព។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៤៨/០៧-ប៉ាយ ហ៊ី និងលេខ ៣៤/១១-លីម ឡាញ ហេតុផលនៃចំណុចវិវាទទី៧)*

ទាក់ទងនឹងភស្តុតាងនៃការរើសអើងសហជីព ជាទូទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើការឆ្លើយបំភ្លឺនៅក្នុងសវនាការ និងធ្វើការពិនិត្យទៅលើភស្តុតាងដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ដើម្បីកំណត់ថាមានការរើសអើងសហជីពកើតមានឡើងដែរ ឬទេ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៣/០៣-តុង ហ្គា ហេតុផលនៃចំណុចវិវាទទី១០, លេខ ១០/០៣-ហ្សាក់ស៊ីនតិច ហេតុផលនៃចំណុចវិវាទទី៤, លេខ ១៩/០៤-ក្បាលកោះ ហេតុផលនៃចំណុចវិវាទទី១, លេខ ១៧/០៧-ឆាម ចិចថាយ ហេតុផលនៃចំណុចវិវាទទី១, លេខ ៥៦/០៩-សាន់តិច ហេតុផលនៃចំណុចវិវាទទី១ និងលេខ ២៨៣/១៤-លៀន ហ្វា (ខេមបូឌា) ហ្គាមិន ខូ., អិលធីឌី ហេតុផលនៃចំណុចវិវាទទី១០)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទាររបស់ភាគីវិវាទ ប្រសិនបើភាគីដែលធ្វើការទាមទារមិនមានភស្តុតាងជាក់លាក់ ដើម្បីសំអាងលើការទាមទារនោះទេ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៦៣/០៤-សាញ វ៉ៃ ហេតុផលនៃចំណុចវិវាទទី៤, លេខ ៩៩/០៦-សៅជ័បាយ ហេតុផលនៃចំណុចវិវាទទី៥, លេខ ៣៣/០៧-ហ្គោល ហ្វេម ហេតុផលនៃចំណុចវិវាទទី៤, លេខ ៥១/០៧-ហ្គោល ហ្វេម ហេតុផលនៃចំណុចវិវាទទី៣ និងលេខ ១៥៤/១៣-បូវយើរ ហ្គាមេន ហ្វេកធើរី ហេតុផលនៃចំណុចវិវាទទី២)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ករណីនេះ ភាគីកម្មករនិយោជិតលើកឡើងថា និយោជករើសអើងសហជីព ព្រោះនិយោជកមិនចាត់វិធានការទៅលើសមាជិកសហជីពផ្សេងដែលធ្វើសកម្មភាពជេរថតកម្មករនិយោជិតនៅកន្លែងការងារក្នុងម៉ោងធ្វើការនោះទេ។ ផ្អែកតាមអំណះអំណាងរបស់ភាគីកម្មករនិយោជិត ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការលើកឡើងនេះ មិនមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា និយោជកបានអនុវត្តមិនស្មើភាពគ្នា ឬមានការរើសអើងសហជីពណាមួយនោះទេ។ យ៉ាងណាមិញ និយោជកបានបញ្ជាក់ថា បានចាត់វិធានការណ៍រួចហើយពេល

THE ARBITRATION COUNCIL

មានការរាយការណ៍មកផ្នែករដ្ឋបាលដោយមានភស្តុតាងច្បាស់លាស់។ លើសពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានពិនិត្យមើលភស្តុតាងដែលភាគីកម្មករនិយោជិតបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល និងរកមិនឃើញមានភស្តុតាងជាក់លាក់ណាមួយដែលអាចបញ្ជាក់ថា និយោជកមានការរើសអើងសហជីពយុវជនខ្មែរនោះដែរ។ ហេតុដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនមានភស្តុតាង ដើម្បីគាំទ្រការអះអាងរបស់ខ្លួនទាក់ទងនឹងការចោទប្រកាន់ថានិយោជកមានការរើសអើងសហជីពយុវជនខ្មែរនោះទេ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត កុំឱ្យនិយោជករើសអើងសហជីពយុវជនខ្មែរ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និងបង្គាប់

**ចំណុចវិវាទទី១ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ដែលនិយោជកបានកាត់ខុស ជូនកម្មករនិយោជិតវិញ។

**ចំណុចវិវាទទី២ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត កុំឱ្យនិយោជករើសអើងសហជីពយុវជនខ្មែរ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ------------------------------